FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# តើត្រូវប្រើប្រាស់ម៉ាស៊ីនបោកស្រូវដូចម្តេច ?

## ហេតុដូចម្តេចបានជាការប្រើប្រាស់ម៉ាស៊ីនបោកស្រូវត្រឹមត្រូវមានសារៈសំខាន់ ?

ការថែទាំ ការរៀបចំកែតម្រូវ ឬបញ្ជាម៉ាស៊ីនបោកមិនត្រឹមត្រូវ អាចបណ្តាលឲ្យការបាត់បង់គ្រាប់ស្រូវ និងការចំណាយប្រេងឥន្ទនៈកើនឡើង ព្រមទាំងបណ្តាលឲ្យប៉ះពាល់ដល់សុខភាពអ្នកកាន់ម៉ាស៊ីនទៀតផង ។

## ការអនុវត្តន៍មុនពេលប្រើប្រាស់ម៉ាស៊ីនបោកស្រូវ

ចូរប្រាកដថា ម៉ាស៊ីនបោកស្ថិតក្នុងស្ថានភាពបច្ចេកទេសល្អ (សូមមើលឯកសារណែនាំស្តីពីការថែទាំ )

| ១. ស្ថានភាពម៉ាស៊ីនបោក | ២. ការត្រួតពិនិត្យម៉ាស៊ីនបោក |
|---|---|
| • ជ្រើសរើសទីតាំងរាបស្មើជិតគំនរកណ្តាប់ | • ត្រួតពិនិត្យស្ថានភាព និងតំណឹងខ្សែពាន |
| • ក្រាលកម្រាលពីក្រោមម៉ាស៊ីនបោក | • ត្រួតពិនិត្យធ្មេញត្បាល់បោក និងភាពជាប់របស់វា |
| • ត្រូវចាប់ភ្ជាប់វិញនូវផ្នែករបស់ម៉ាស៊ីន បើសិនជាបានដោះវាចេញពីមុន | • បង្វិលត្បាល់បោកមួយរយៈ ដើម្បីពិនិត្យមើលដំណើរការរបស់វា |
| • ដាក់ម៉ាស៊ីនបោកដោយលៃយ៉ាងណាឲ្យចំបើងដែលបាញ់ចេញពីម៉ាស៊ីនមានទិសដៅស្របជាមួយទិសដៅខ្យល់ | • ត្រួតពិនិត្យប្រេងបាតចលករ (ក្បាលម៉ាស៊ីន) និងប្រេងម៉ាស៊ូត |
| | • ត្រួតពិនិត្យមើលខ្លាញ់រ៉ូឡឺម៉ង់(បាដាង) |

## ការបញ្ជាម៉ាស៊ីនបោកស្រូវ

ដើម្បីដំណើរការម៉ាស៊ីនបោកស្រូវ គេត្រូវការមនុស្សពី ៤ ទៅ ៥ នាក់ សម្រាប់ជញ្ជូនកណ្តាប់ដាក់លើថាសទម្រ រុញកណ្តាប់បញ្ចូលទៅក្នុងម៉ាស៊ីន និង សម្រាប់ច្រកស្រូវដែលបោករួច ។

- បញ្ឆេះម៉ាស៊ីន និងត្រួតពិនិត្យល្បឿនត្បាល់ ឬ ស៊ីឡាំងបោក
- គរកណ្តាប់ស្រូវលើថាសទម្រដោយដាក់ចុងកណ្តាប់ទៅខាងមាត់ច្រកកណ្តាប់

➢ រុញស្រូវបញ្ចូលទៅក្នុងត្បាល់បោកក្នុងបរិមាណដូចគ្នា។កែសម្រួលបរិមាណស្រូវចូលក្នុងត្បាល់បោកទៅតាមល័ក្ខខ័ណ្ឌនៃស្រូវ រហូតដល់កម្រិតអតិបរមា ដោយមិនត្រូវឲ្យចលករធ្វើការលើសបន្ទុកឡើយ ។

➢ កែសម្រួលប្រព័ន្ធសំអាតឲ្យសមស្របទៅនឹងលក្ខខណ្ឌនៃការបោក ៖

- បិទសន្ទះកែសម្រួលខ្យល់ឲ្យជិត រួចបើកវាបន្តិចម្តងៗ រហូតដល់មានគ្រាប់ស្រូវទុំតិចតួចប៉ើងហួសសន្ទះទប់នៅចុងកញ្ច្រែងញាក់
- កែសម្រួលមុំទ្រេតរបស់សន្ទះទប់ចុងកញ្ច្រែងញាក់

➢ ជានិច្ចកាលត្រូវប្រើឈើវែង សម្រាប់កាយយកកម្ទេចចំបើងចេញពីរន្ធកញ្ច្រែងញាក់ ដើម្បីការពារការស្ទះរន្ធកញ្ច្រែង ។





**ការធ្វើឲ្យប្រសើរបំផុតសម្រាប់ការបញ្ហាម៉ាស៊ីនបោកស្រូវ**

- ○ **ចំបើងវែង** : ទប់កណ្តាប់ស្រូវនៅមាត់ច្រកស្រូវចូលបន្តិច ដើម្បីឲ្យគ្រាប់ស្រូវមួយចំនួនជ្រុះសិន
- ○ **ចំបើងខ្លី** : ត្រូវបោកចំបើងម្តងទៀត បើកត់សំគាល់ឃើញថាមានការបាត់បង់ខ្ពស់
- ○ **ពូជស្រូវពិបាកបោក** : តំឡើងបន្ទះធ្មេញទប់ ។ វាការពារមិនឲ្យចំបើងទៅរុំជុំវិញស៊ីឡាំង និងបង្កើននូវការបោក ។ ការចាប់បន្ថែមបន្ទះធ្មេញទប់នេះធ្វើឡើងតែក្នុងករណីចាំបាច់ប៉ុណ្ណោះពីព្រោះវាធ្វើឲ្យសមត្ថភាពបោកថយចុះ និងបង្កើនបរិមាណកម្ទេចចំបើងតូចៗ ។

